**វេទិកាពលរដ្ឋ**

**PEOPLE FORUM**

# វេទិកាពលរដ្ឋ

# PEOPLE FORUM

សហរដ្ឋអាមេរិក ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣

## សេចក្តីថ្លែងការណ៍

## សូមទម្លាក់ចោលបទចោទប្រកាន់ និងដោះលែង លោក ហ៊ុន កុសល និងលោក យឹម ស៊ីណន

**វេទិកាពលរដ្ឋ** សូមអំពាវនាវដល់រដ្ឋាភិបាលរបស់លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ទម្លាក់ចោលបទចោទ និងដោះលែងលោក **ហ៊ុន កុសល** និងលោក **យឹម ស៊ីណន** សកម្មជននយោបាយនៃគណបក្សសង្គ្រោះជាតិ ដែលត្រូវបានចាប់ខ្លួននៅទីក្រុងភ្នំពេញ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣ បន្ទាប់ពីបានទិតៀនលោក **ហ៊ុន សែន** លើបណ្ដាញសង្គម ពាក់ព័ន្ធនឹងរូបភាព**ព្រះមហាក្សត្រ** ព្រះរាជទានព្រះអគ្គីជ័យកីឡា សម្រាប់ព្រឹត្តិការណ៍ប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២។ ការទិតៀនរបស់លោក **ហ៊ុន កុសល** និងលោក **យឹម ស៊ីណន** ជាទម្រង់សេរីភាពក្នុងការបញ្ចេញមតិ មិនមែនជាការញុះញង់ ដូចការចោទប្រកាន់ឡើយ។

ការចាប់ខ្លួនសកម្មជននយោបាយទាំងពីរខាងលើ ជាការរំលោភរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៤១ កថាខណ្ឌទី១ ចែងថា *«ប្រជាពលរដ្ឋខ្មែរ **មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន** សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ»*។ ជាងនេះទៀត ការចាប់ខ្លួននេះ ក៏ជាការរំលោភលើសេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្ស មាត្រា១៩ ចែងថា *«មនុស្សគ្រប់រូប មានសិទ្ធិសេរីភាព ក្នុងការបញ្ចេញមតិ និងការសម្តែងមតិ។ សិទ្ធិនេះរាប់បញ្ចូលទាំងសេរីភាពក្នុងការបញ្ចេញមតិ ដោយគ្មានការរជ្រៀតជ្រែក និងសេរីភាពក្នុងការស្វែងរកការទទួលនិងការផ្សព្វផ្សាយព័ត៌មាន និងគំនិតនានាដោយ គ្មានព្រំដែន ទោះតាមរយៈមធ្យោបាយសម្តែងមតិណាមួយក៏ដោយ»*។

**វេទិកាពលរដ្ឋ** លើកទឹកចិត្តដល់រដ្ឋាភិបាលកម្ពុជា ទម្លាក់ចោលបទចោទប្រកាន់នានា និងដោះលែងអ្នកនយោបាយ និងសកម្មជនសង្គមទាំងឡាយ ដើម្បីជាប្រយោជន៍លើកមុខមាត់ដល់ប្រទេសជាតិ ស្ការលទ្ធិប្រជាធិបតេយ្យ និងការផ្សះផ្សាជាតិ។

**អគ្គលេខាធិការវេទិកាពលរដ្ឋ**

Séng

**អ៊ាប សេង**



................................................................................................................................................

Address: 58 Poplar Street, Plains PA 18705, USA